*សេចក្តីប្រកាសព័ត៌មាន*
*ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១២*

*សម្ព័ន្ធប្រជានេសាទកម្ពុជា (ទន្លេសាប ទន្លេមេគង្គ និងតំបន់ឆ្នេរ)*
*អំពាវនាវបញ្ឈប់ការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២*

**សម្ព័ន្ធប្រជានេសាទកម្ពុជា** បានផ្ញើលិខិតជូនទៅសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងនាយករដ្ឋមន្ត្រីនៃប្រទេសវៀតណាមនៅថ្ងៃខែឆ្នាំដដែលនេះ។

**សម្ព័ន្ធប្រជានេសាទកម្ពុជា** ជាអង្គការមហាជនមួយដែលកើតឡើងពីការចងបណ្តាញគ្នារវាងសហគមន៍នេសាទ និងប្រជានេសាទក្នុងប្រទេសកម្ពុជា ដែលកើតឡើងនៅឆ្នាំ២០០៥ មាន៣តំបន់ (តំបន់ទន្លេសាបមាន៦ខេត្តជុំវិញបឹងទន្លេសាប តំបន់ឆ្នេរមាន៣ខេត្ត និងតំបន់មេគង្គមាន៥ខេត្ត) ។

ទំនប់វារីអគ្គិសនីដែលបានសាងសង់នៅផ្នែកខាងលើទន្លេមេគង្គ ក្នុងប្រទេសចិនពិតជាបានផ្លាស់ប្តូររបបទឹក និងមានឥទ្ធិពលដល់ធនធានត្រីនៅបឹងទន្លេសាប។ នៅពេលគំរោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីត្រូវបានសាងសង់ឡើង សហគមន៍រស់នៅជុំវិញបឹងទន្លេសាប ពិតជាទទួលរងផលប៉ះពាល់ដល់ធនធានជលផលមានការប្រែប្រួល និងឈានទៅរកការបាត់បង់ជាបណ្តើរៗ។

ទន្លេសាបមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយទន្លេមេគង្គ ដែលបានផ្តល់នូវធនធានត្រី ជីវជាតិសំរាប់ដំណាំស្រូវ និងដំណាំកសិកម្មដទៃទៀត។ ប្រជាពលរដ្ឋប្រមាណ១.២លាននៅចន្លោះផ្លូវជាតិលេខ៥ និងលេខ៦ ពឹងអាស្រ័យទាំងស្រុងទៅនឹងបឹងទន្លេសាប ដែលគេបានចាត់ទុកថាជាបេះដូងនៃប្រទេសកម្ពុជា។ ដែលវាបានផ្តល់ផលត្រីយ៉ាងច្រើនមហិមាសំរាប់ផ្គត់ផ្គង់ និងទ្រទ្រង់ជីវភាពរស់នៅបានយ៉ាងល្អប្រសើរ និងការនាំចេញ។ ក្នុងបឹងទន្លេសាបមានជីវសាស្ត្រចំរុះដូចជា៖ ពួកមច្ឆាជាតិប្រមាណជា ២៥០-៣៥០ ប្រភេទ ពពួកល្មូន (ឧរង្គសត្វ) ប្រមាណជា ៤០-៦០ ប្រភេទ ពពួកបក្សី (សកុណជាតិ) ប្រមាណជា ២០០-២៥០ ប្រភេទ និងថនិកសត្វ (សត្វដែលចិញ្ចឹមកូនដោយទឹកដោះ) មានប្រមាណជា ៤០-៥០ ប្រភេទ ហើយវានិងបាត់បង់ធនធានជលផលក្នុងទន្លេ ដទៃទន្លេ និងបឹងទន្លេសាបប្រសិនបើទំនប់វារីអគ្គិសនីសេសានក្រោម២នឹងត្រូវបានសាងសង់ក្នុងខេត្តស្ទឹងត្រែង ហើយជាបន្ទុកដ៏ធំធេងសំរាប់រាជរដ្ឋាភិបាល និងជះឥទ្ធិពលដល់ប្រជាពលរដ្ឋរស់នៅជុំវិញតំបន់នោះ និងទូទាំងប្រទេសដែលត្រូវដោះស្រាយ។

« ប្រសិនបើទំនប់វារីអគ្គិសនីសេសានក្រោម២ត្រូវបានសាងសង់ វានឹងប៉ះពាល់ដល់កំណើនល្បាប់ ដែលវាមានសារសំខាន់សំរាប់អាហាររូបត្ថម្ភ និងផ្តល់ជីជាតិសំរាប់ដំណាំកសិកម្មរបស់យើង និងតំបន់មេគង្គរបស់ប្រទេសវៀតណាម។ អ្នកជំនាញការមកពីមជ្ឈមណ្ឌលអន្តរជាតិសំរាប់ការគ្រប់គ្រងបរិស្ថានក្នុងប្រទេសវៀតណាមបាននិយាយថា ទំនប់វារីអគ្គិសនីកាត់បន្ថយ ៦ ទៅ ៨ភាគរយនៃកំណើនល្បាប់ក្នុងទន្លេមេគង្គ»។

តាមរបាយការណ៍វិទ្យាសាស្ត្ររបស់វិទ្យាស្ថានជាតិអប់រំវិទ្យាសាស្ត្រ PNAS នៃសហរដ្ឋអាមេរិក បានបង្ហាញថាប្រសិនបើទំនប់វារីអគ្គិសនីសេសានក្រោម២ នឹងត្រូវសាងសង់វា បណ្តាលអោយជីវម៉ាសរបស់ត្រីថយចុះ ៩.៣ភាគរយ។ ប្រភេទត្រីច្រើនជាង ៥៦ ប្រភេទនឹងជួបនូវគ្រោះមហន្តរាយ។ នេះមានន័យថាចំណូលពីធនធានជលផលប្រហែលជា ៨០០

លានដុល្លាក្នុង១ឆ្នាំដែលចំនួននេះស្មើនឹងតំលៃចំណាយលើគំរោងទំនប់ស្មើនឹង ៨១៦លានដុល្លា។ រីឯការសិក្សារបស់គណកម្មការជាតិទន្លេមេគង្គបានប៉ាន់ប្រមាណតម្លៃសរុបនៃមុខរបរនេសាទនៅក្នុងអាងទន្លេមេគង្គ គឺមានតម្លៃចន្លោះពី ៥,៦ ទៅ ៩,៤ ពាន់លានដុល្លាសហរដ្ឋអាមេរិក។ ដូច្នេះទំនប់វារីអគ្គីសនីសេសានក្រោម២ នឹងបណ្តាលឲ្យមានការខាតបង់ថវិកាពី ៥២០ ទៅ ៨៧៤ លានដុល្លាសហរដ្ឋអាមេរិកក្នុងមួយឆ្នាំៗ ចំពោះប្រជាពលរដ្ឋក្រីក្រ។

ទំនប់វារីអគ្គីសនីសេសានក្រោម២ នឹងប្រតិបត្តិការណ៍ដោយក្រុមហ៊ុនអគ្គីសនីវៀតណាម (EVN គឺជាក្រុមហ៊ុនវៀតណាម) និងក្រុមហ៊ុនរ៉ូយាល់គ្រុប (របស់ប្រទេសកម្ពុជា) នឹងបង្កឲ្យមានតាំងទីលំនៅថ្មីចំនួន ៥០០០ (ប្រាំពាន់នាក់) និងប្រជាពលរដ្ឋប្រមាណ១០០០០០ នាក់ផ្សេងទៀត (ដប់ម៉ឺននាក់) នៅខេត្តស្ទឹងត្រែង ខេត្តរតនៈគីរី និងខេត្តមណ្ឌលគីរី ព្រមទាំងប្រជាពលរដ្ឋរាប់ពាន់លាននាក់ឯទៀតដែលរស់នៅជាប់អាងទន្លេមេគង្គ នឹងទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីខ្សែទឹកផ្នែកខាងក្រោម នឹងបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានជាច្រើនទៅលើមុខរបរនេសាទនៅក្នុងប្រទេសកម្ពុជា រួមទាំងបឹងទន្លេសាប និងដទៃទន្លេមេគង្គ ព្រមទាំងតំបន់ផ្សេងទៀតនៃប្រទេសវៀតណាម ឡាវ និងថៃ។


**<u>អ្នកទំនាក់ទំនង៖</u>**

**លោក ឌឹម សាវ៉ាត នាយកប្រតិបត្តិ អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល** ទូរស័ព្ទលេខ ០១២ ៨៥៨ ៤២០ email: savath@fact.org.kh

**សម្ព័ន្ធប្រជានេសាទកម្ពុជា៖**

1. ឡុង សុចេត ទូរស័ព្ទលេខ ០១១ ៣៦៣ ១៣៤ email: longsochet@yahoo.com
2. ឡេង បូ ទូរស័ព្ទលេខ ០៩២ ៤៣៨ ២៦៦
3. ឡោ ឈាន ទូរស័ព្ទលេខ ០១២ ២៤៨ ៦៣៥
4. កាំ សុធីរ ទូរស័ព្ទលេខ ០៧៦ ៧០០ ៨៣៩៩


**<u>ព័ត៌មានលំអិត៖</u>**

របាយការណ៍សិក្សាសូមចូលទៅកាន់គេហទំព័រ www.pnas.org/content/early/2012/03/09/1201423109.short